អង្គភាពសវនកម្មផ្ទៃក្នុង

# អត្ថបទប្រចាំខែ

លេខ ៤៩/២៦ ចេញផ្សាយ ខែមករា ឆ្នាំ២០២៦

## និដ្ឋភាពទូទៅនៃទ្រព្យសកម្ម

ដើម្បីឲ្យស្ថាប័នមួយអាចដំណើរការទៅបានប្រកបដោយចីរភាព ស្ថាប័ននោះត្រូវមានធាតុផ្សំសំខាន់ៗដូចជា៖ ធនធានមនុស្ស, ហិរញ្ញវត្ថុ, ទ្រព្យសកម្ម, ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង, និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានជាដើម។ ក្នុងនោះ ទ្រព្យសកម្ម គឺជាធាតុដ៏សំខាន់មួយក្នុងចំណោមធាតុសំខាន់ៗដទៃទៀត ដែលទាមទារឲ្យស្ថាប័ននីមួយៗត្រូវគិតគូរ និងគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងភាពសន្សំសំចៃ ដើម្បីធានាដល់ប្រតិបត្តិការយូរអង្វែងរបស់ស្ថាប័ន។

### តើទ្រព្យសកម្មជាអ្វី?




### និយមន័យ

**ទ្រព្យសកម្ម** គឺជាធនធានដែលគ្រប់គ្រងដោយស្ថាប័ន (ក្រុមហ៊ុន បុគ្គល ឬរដ្ឋាភិបាល)ជាលទ្ធផលនៃព្រឹត្តិការណ៍កន្លងមក (ទិញ, បង្កើត, ការផ្ទេរ ឬអំណោយ...) ដែលផ្តល់ផលសេដ្ឋកិច្ចនាពេលអនាគត។ ទ្រព្យសកម្មមានដូចជា៖ ដី, អគារ, បរិក្ខារ, រថយន្ត, ប្រកាសនីយបត្រតក្កកម្ម, អាជ្ញាបណ្ណ, សិទ្ធថតចម្លង និងសិទ្ធិពិសេស។ល។ ទ្រព្យសកម្មគឺជាអ្វីដែលគាំទ្រដល់សក្តានុពលនៃការរកប្រាក់ចំណូល និងការធ្វើប្រតិបត្តិការរបស់ស្ថាប័ន។ ជាទូទៅទ្រព្យសកម្មត្រូវបានបែងចែកជា ២ ប្រភេទ រួមមាន៖ **ទ្រព្យសកម្មរយៈពេលខ្លី** និង**ទ្រព្យសកម្មរយៈពេលវែង**។

### ទ្រព្យសកម្មរយៈពេលខ្លី

**ទ្រព្យសកម្មរយៈពេលខ្លី** គឺជាទ្រព្យសកម្មដែលអាចលក់ និងបំប្លែងទៅជាសាច់ប្រាក់ ឬប្រើប្រាស់បានក្នុងរយៈពេល ១ ឆ្នាំ និងបំពេញកាតព្វកិច្ចហិរញ្ញវត្ថុបានលឿន រួមមានដូចជា៖ សាច់ប្រាក់ ឬសមមូលសាច់ប្រាក់, មូលបត្ររយៈពេលខ្លី, គណនីត្រូវទទួល, សន្និធិ, ចំណាយបង់មុន និងការវិនិយោគរយៈពេលខ្លី។

### ទ្រព្យសកម្មរយៈពេលវែង

**ទ្រព្យសកម្មរយៈពេលវែង** គឺជាទ្រព្យដែលប្រើប្រាស់បានយូរ និងជាក់ស្តែងដែលអាជីវកម្មមាននិងប្រើប្រាស់ដើម្បីបង្កើតប្រាក់ចំណូល ប៉ុន្តែមិនអាចបំប្លែងជាសាច់ប្រាក់បានក្នុងរយៈពេលមួយឆ្នាំ មានទម្រង់ដូចជា៖ ទ្រព្យសកម្មរូបី, ទ្រព្យសកម្មអរូបីយ៍, ទ្រព្យសកម្មហិរញ្ញវត្ថុ និងទ្រព្យសកម្មឌីជីថល។

**ទ្រព្យសកម្មរូបីយ៍** គឺជាទ្រព្យដែលអាចសំគាល់ថាជាទ្រព្យសកម្មដែលមានរូបរាង ដូចជា៖ ដី, អាគារ, អចលនទ្រព្យ, គ្រឿងចក្រ, យានយន្ត និងសម្ភារៈបរិក្ខារ។

**ទ្រព្យសកម្មអរូបីយ៍** គឺជាទ្រព្យដែលអាចសំគាល់ថាជាទ្រព្យសកម្មដែលគ្មានរូបរាង ដូចជា៖ សិទ្ធិបញ្ញា, អាជ្ញាបណ្ណ និងសញ្ញាពាណិជ្ជកម្មជាដើម។

**ទ្រព្យសកម្មហិរញ្ញវត្ថុ** គឺជាទ្រព្យដែលស្ថាប័ន ឬអង្គភាពរបស់រដ្ឋាភិបាលអាចរកចំណូលបានពីទ្រព្យទាំងអស់នេះ ដោយរំពឹងថានឹងត្រឡប់មកវិញនាពេលអនាគតដល់ស្ថាប័ន និងរក្សានៃតម្លៃ រួមមានដូចជា៖ វិញ្ញាបនបត្រប្រាក់បញ្ញើ, បណ្ណភាគហ៊ុន, និងសញ្ញាបណ្ណ។

**ទ្រព្យសកម្មឌីជីថល** គឺជាវត្ថុនៃតម្លៃណាមួយដែលមានក្នុងទម្រង់ឌីជីថល ដូចជា៖ រូបថត, ឯកសារ និងវីដេអូ ក៏ដូចជាទ្រព្យសម្បត្តិដែលមានមូលដ្ឋានលើ Blockchain ដូចជា៖រូបិយបណ្ណ Bitcoin និង NFTs ដែលផ្តល់ភាពជាម្ចាស់ និងការផ្ទេរតែមួយគត់តាមរយៈសៀវភៅបញ្ជីចែកចាយដូចជា Blockchain ជាដើម។

ជារួម ទ្រព្យសកម្ម គឺជាធនធានចម្បងរបស់ស្ថាប័ន មានតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រប្រតិបត្តិការ និងការសម្រេចគោលដៅរបស់ស្ថាប័ន។ ការគ្រប់គ្រងទ្រព្យសកម្មបានល្អជួយបង្កើនតម្លៃនៃការប្រើប្រាស់ធនធាន កាត់បន្ថយហានិភ័យ ធានាបានការទទួលខុសត្រូវក្នុងការគ្រប់គ្រង និងគាំទ្រការអភិវឌ្ឍដោយចីរភាពរបស់ស្ថាប័ន។

**អត្ថបទដោយ៖** លោក **ជាតិ មានឥទ្ធិពលពិត**

**ឯកសារយោង៖** ឧត្តមានុវត្តន៍នៃការគ្រប់គ្រងទ្រព្យសកម្មរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)

អត្ថបទអប់រំខ្លីៗស្តីពីសវនកម្មត្រូវបានរៀបរៀងដោយមន្ត្រីរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ អ.ស.ហ.

ទស្សនៈដែលមាននៅក្នុងអត្ថបទនេះ មិនមែនជាទស្សនៈរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ អ.ស.ហ. ទេ ប៉ុន្តែជាទស្សនៈរបស់អ្នករៀបរៀងផ្ទាល់ខ្លួន ឬរបស់ក្រុមការងារ។

ស្កេនទាញយកអត្ថបទស្តីពីសវនកម្មផ្សេងទៀត

Facebook Telegram Website